**ប្រធានអង្គការ UNESCO**

**សំដែងការព្រួយបារម្ភចំពោះការបាត់បង់ជីវិតមនុស្សនៅខាងក្រៅប្រាសាទបុរាណរបស់កម្ពុជា**

ប្រភព៖ មជ្ឈមណ្ឌលព័ត៌មានរបស់ អ.ស.ប

២១ ខែ តុលា ឆ្នាំ ២០០៦ -ប្រធានអង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌របស់ អ.ស.ប UNESCO បានសំដែងចេញនូវការព្រួយ បារម្ភយ៉ាងខ្លាំងរបស់លោកចំពោះការប៉ះទង្គិចគ្នាថ្មីៗនេះរវាងទាហានថៃ និងទាហានកម្ពុជានៅខាងក្រៅប្រាសាទ ព្រះវិហារដែលបណ្តាលអោយមនុស្ស២នាក់បាត់បង់ជីវិត ។

លោក Koichiro Matsuura អគ្គនាយករបស់អង្គការ UNESCO បានបង្ហាញនូវកិច្ចប្រឹងប្រែងម្តងហើយម្តងទៀតនូវគំនិតផ្តួចផ្តើម របស់អង្គការ UNESCO ដើម្បីលើកកំពស់នូវកិច្ចសហការ និងកិច្ចសន្ទនាគ្នា ។

លោកក៏បានថ្លែងបន្ថែមទៅកាន់លោកអគ្គលេខាធិការ អ.ស.ប Ban Ki -moon ដែលនៅក្នុងសេចក្តីប្រកាសកាលពីថ្ងៃទី១៥ ខែ តុលា បានអំពាវនាវឱ្យភាគីទាំងពីរ អនុវត្តន៍ការដាក់កំហិតឱ្យបានខ្លាំងក្លា និងជំរុញឱ្យមានកិច្ចពិភាក្សាទ្វេភាគីឱ្យបានរួសរាន់ ដើម្បីឱ្យភាពមិនត្រូវគ្នាអាចដោះស្រាយបានដោយសន្តិវិធី ។ ប្រាសាទព្រះវិហារដែលត្រូវបានកសាងឡើងនៅសតវត្សរ៍ ទី១១ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជី បិតិកភ័ណ្ឌពិភពលោករបស់អង្គការ UNESCO កាលពីខែកក្កដា ដោយសារតែមានតំលៃជាសកលដ៏លើសលុប ។

អង្គការ UNESCO បានកត់សំគាល់ថាការដាក់បញ្ចូលជាបិតិកភ័ណ្ឌពិភពលោក គឺទាក់ទងទៅនឹងការទទួលខុសត្រូវជាសមូលភាពរបស់សហគមន៍ អន្តរជាតិដើម្បីធានាដល់កិច្ចការពារនូវបិតិភ័ណ្ឌទាំងនោះ ។

www.information.gov.kh